# ព្រឹត្តិបត្រព័ត៌មាន

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)

គ.ជ.ប NEC BULLETIN

លេខ ១០ ចេញផ្សាយថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣

Issue 10 : 29 / 8 / 2023


## ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

(ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣)

# សម្តេចក្រឡាហោម ស ខេង និងឯកឧត្តម ប្រាជ្ញ ចន្ទ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបិទសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣




(រូបខាងឆ្វេង) សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប

សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលរៀបចំឡើងដោយគណៈកម្មាធិការ-




តទៅទំព័រទី២


**មាតិកា៖** **ទំព័រ**


- សម្តេចក្រឡាហោម ស ខេង និងឯកឧត្តម ប្រាជ្ញ ចន្ទ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតបូកសរុបការងារ ...១
- ឯកឧត្តម នុត សុខុម អនុប្រធាន គ.ជ.ប អញ្ជើញជាអធិបតីក្នុងពិធីបើកសន្និបាតបូកសរុបការងារបោះឆ្នោត ................៦
- លទ្ធផលនៃសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ............................៨
- កម្រងរូបភាពសកម្មភាពពិភាក្សាតាមក្រុម និងតាមប្រធានបទជំនាញចំនួន ៥ ក្នុងពិធីសន្និបាតបូកសរុបការងារ ........១២

តមកពីទំព័រទី១ **សម្តេចក្រឡាហោម ...**

ជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានបិទបញ្ចប់នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និងឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប។

សន្និបាតនេះ បានប្រព្រឹត្តទៅនៅសាលមហោស្រពស្ទឹងសង្កែខេត្តបាត់ដំបង ហើយនាឱកាសនោះ សម្តេចក្រឡាហោម **ស ខេង** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមសម្តេចផ្ទាល់ បានសម្តែងនូវការកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ.ជ.បគ្រប់លំដាប់ថ្នាក់ អាជ្ញាធរ កម្លាំងមានសមត្ថកិច្ច គណបក្សនយោបាយ អ្នក-



សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សង្កេតការណ៍ជាតិ អន្តរជាតិ អ្នកពាក់ព័ន្ធនានា ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលបានចូលរួមអនុវត្ត និងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនស្របតាមច្បាប់បោះឆ្នោត បទបញ្ជា នីតិវិធី និងក្រមសីលធម៌នានា សម្រាប់ការបោះឆ្នោតប្រកបដោយស្មារតីទទួលខុសត្រូវ និងភាពថ្លៃថ្នូរក្នុងនាមជាប្រជាជាតិខ្មែរដើម្បីផលប្រយោជន៍ខ្មែរ ដែលធ្វើឱ្យការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នេះ ទទួលបាននូវលទ្ធផល ដ៏ល្អប្រសើរប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ ក្រោមបរិយាកាសសន្តិភាព មានស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ និងមានសុវត្ថិភាព។

សម្តេចបានបញ្ជាក់បន្ថែមថា លទ្ធិប្រជាធិបតេយ្យ និង



គណៈអធិបតីអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

ការបោះឆ្នោត គឺជាដំណើរការមួយក្នុងការចូលរួមថែរក្សា ការពារប្រជាជាតិ និងប្រជាជនឱ្យរស់រានក្នុងភាពថ្លៃថ្នូរ សម្បូរសប្បាយ ស្របតាមឆន្ទៈរបស់អ្នកបោះឆ្នោត មិនមែនជាដំណើរការធ្វើឱ្យសង្គមជាតិមានភាពវឹកវរ អស្ថិរភាព ដោយសារតែមានទស្សនៈនយោបាយខុសគ្នានោះឡើយ។

ស្របទៅនឹងការលើកឡើងរបស់ សម្តេចក្រឡាហោម **ស ខេង** ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានកត់សម្គាល់ឃើញថា ការបោះឆ្នោតសកល ឆ្នាំ២០២៣ បានប្រព្រឹត្តទៅមានតម្លាភាព សន្តិភាព សេរី និងយុត្តិធម៌ សម្រាប់ការរាប់សន្លឹកឆ្នោតដោយដៃមានលំដាប់លំដោយ ហើយការបញ្ជូនលទ្ធផលពីការិយាល័យបោះឆ្នោត មកគណៈកម្មការរៀបចំការបោះឆ្នោតតាមលំដាប់ថ្នាក់ និងតាមប្រព័ន្ធអេឡិចត្រូនិក បញ្ជាក់អំពីតម្លាភាពយ៉ាងខ្លាំងគួរឱ្យទុកចិត្តបាន។ កត្តាទាំងនេះហើយ គឺជាសូចនាករបង្ហាញពីភាពជោគជ័យនៃដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងជាសមិទ្ធផលថ្មីមួយទៀតនៃលទ្ធិប្រជាធិបតេយ្យ និងការកែទម្រង់ការបោះឆ្នោតនៅកម្ពុជា។ ជោគជ័យដ៏ត្រចះត្រចង់ដែលសម្រេចបាននេះ គឺអាស្រ័យដោយមានការចូលរួមចំណែកដ៏ថ្លៃថ្លាប្រកបដោយស្មារតីទទួលខុស



ភាគីពាក់ព័ន្ធអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត



ឯកឧត្តម ប្រាជ្ញ ចន្ទ ប្រធាន គ.ជ.ប

ត្រូវខ្ពស់ពីស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អាជ្ញាធរដែនដីគ្រប់កម្រិត ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល សមាគមអ្នកសារព័ត៌មានជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត ជាពិសេសប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ដែលបានអញ្ជើញទៅបោះឆ្នោតយ៉ាងច្រើនកុះករ ប្រកបដោយទឹកមុខរីករាយ និងគ្មានការភ័យខ្លាច។

ឯកឧត្តមប្រធាន គ.ជ.ប បានជម្រាបជូនថា ឆ្លងតាមការពិភាក្សារបស់អង្គសន្និបាត អំពីដំណាក់កាលសំខាន់ៗនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ កន្លងមកនេះ យើងបានរកឃើញចំណុចខ្លាំងដែលជាបទពិសោធន៍សម្រាប់អនុវត្តបន្ត មានជាអាទិ៍៖

- ការរៀបចំចងក្រងបទបញ្ញា និងនីតិវិធីបានត្រឹមត្រូវតាមច្បាប់ ដោយមានការចូលរួមផ្តល់មតិ និងយោបល់ពីគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល



មន្ត្រីគ.ជ.ប និងភាគីពាក់ព័ន្ធអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

និងភាគីពាក់ព័ន្ធ និងការផ្សព្វផ្សាយបានយ៉ាងទូលំទូលាយ ធ្វើឱ្យដំណើរការអនុវត្តក្នុងក្របខណ្ឌបច្ចេកទេសបានរលូនល្អ ទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

- ការកសាងផែនការមេ ផែនការសកម្មភាព ប្រតិទិនការងារ និងគម្រោងថវិកាចំណាយបានត្រឹមត្រូវ សមស្របតាមពេលវេលា តាមតម្រូវការ និងសំណូមពរជាក់ស្តែងនៃការងារ បានបង្កឱ្យមានភាពងាយស្រួលក្នុងការអនុវត្តភារកិច្ចតាមជំហាននីមួយៗ។



ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

- ការតាមដាន ការត្រួតពិនិត្យ និងការណែនាំការអនុវត្តបានទៀងទាត់ និងទាន់ពេលវេលារបស់ថ្នាក់ដឹកនាំ គ.ជ.ប អគ្គលេខាធិការដ្ឋាន គ.ជ.ប និងអគ្គនាយកដ្ឋានជំនាញ គឺជាវិធានការដ៏សមស្រប ឆ្លើយតបទៅនឹងសំណូមពរ តម្រូវការ និងសភាពការណ៍វិវឌ្ឍន៍ជាក់ស្តែងនៃដំណើរការរៀបចំការបោះឆ្នោត។
- ការដាក់បញ្ចូលបច្ចេកវិទ្យាព័ត៌មាន ដើម្បីធ្វើទំនើបកម្មនៃដំណើរការរៀបចំការបោះឆ្នោត ជាប្រការមិនអាចខ្វះបាន ក្នុងការគាំទ្រដល់ដំណើរការរៀបចំការបោះឆ្នោត ជាអាទិ៍៖
  - កម្មវិធីគ្រប់គ្រងការរៀបចំបញ្ជីបោះឆ្នោត
  - កម្មវិធីគ្រប់គ្រងការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ជូនអ្នកបោះឆ្នោត



គណៈអធិបតីអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

- កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ
- កម្មវិធីគ្រប់គ្រងសំណុំរឿង និងរបាយការណ៍ពាក់ព័ន្ធនឹងពាក្យបណ្តឹង
- កម្មវិធីគ្រប់គ្រងលទ្ធផលបោះឆ្នោត (លទ្ធផលបឋម លទ្ធផលបណ្តោះអាសន្ន និងលទ្ធផលផ្លូវការ)

- ការជ្រើសរើសមន្ត្រីបោះឆ្នោត ដែលមានសមត្ថភាព បទពិសោធន៍ល្អក្នុងការងារ មានជំហរអព្យាក្រឹត មានសីលធម៌ និងសាមគ្គីភាពផ្ទៃក្នុងល្អ គឺជាកត្តាមួយក្នុងចំណោមកត្តាសំខាន់ៗ ដែលកំណត់ជោគជ័យនៃការបោះឆ្នោត
- កិច្ចសហការ ការចូលរួមសហការ និងការគាំទ្រយ៉ាងសកម្មពីគ្រប់ស្ថាប័នពាក់ព័ន្ធដែលរួមមានគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មានជាតិ អន្តរជាតិ ព្រមទាំងប្រជាពលរដ្ឋទូទាំងប្រទេស គឺជាកត្តាមិនអាចខ្វះបានក្នុងការកំណត់ជោគជ័យនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យ



មន្ត្រី គ.ជ.ប អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

សេរី ពហុបក្ស នៅកម្ពុជា

- ការពង្រឹងទំនាក់ទំនង និងកិច្ចសហការល្អជាមួយគ្រប់ភាគីពាក់ព័ន្ធ ពិសេសជាមួយអាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ ធ្វើឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតធានាបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈល្អ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង។

ឯកឧត្តម **ប្រាជ្ញ ចន្ទ** បានថ្លែងទៀតថា ទន្ទឹមនឹងគុណសម្បត្តិដែលយើងទទួលបាន អង្គសន្និបាតក៏បានរកឃើញនូវចំណុចខ្វះខាតមួយចំនួនក្នុងដំណើរការរៀបចំការបោះឆ្នោត ដើម្បីយកមកពិនិត្យពិចារណា រកដំណោះស្រាយសមស្របសំដៅធានាឱ្យការបោះឆ្នោតនាពេលខាងមុខ កាន់តែមានភាពល្អប្រសើរឡើង ក្នុងនោះ៖



មន្ត្រី គ.ជ.ប អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

- ត្រូវត្រួតពិនិត្យ កែសម្រួលនូវបទបញ្ញា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតដែលមានគុណភាពខ្ពស់ ឆ្លើយតបទៅនឹងការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ពិសេសការធានាបាននូវការគ្រប់គ្រងទិន្នន័យប្រជាពលរដ្ឋល្អដែលបានអញ្ជើញចេញទៅបោះឆ្នោតជាសកល
- ត្រូវពង្រឹង និងលើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការដឹកនាំក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) អនុវត្តភារកិច្ចធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែល គ.ជ.ប បានធ្វើប្រតិភូកម្មអំណាចឱ្យ
- ត្រូវត្រួតពិនិត្យកែសម្រួលបទបញ្ញា និងនីតិវិធី ការដាក់



គណៈអធិបតីអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោត និងពាក្យបណ្ដឹងពាក់-ព័ន្ធនឹងអំពើល្មើសនឹងជំពូកទី១០ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រួមទាំងយន្តការដោះស្រាយបណ្ដឹង សម្រាប់បទល្មើសបោះឆ្នោតដែលជនណាបានប្រព្រឹត្ត

- ត្រូវលើកកម្ពស់សមត្ថភាពយល់ដឹងដល់មន្ត្រីបោះ-ឆ្នោតគ្រប់លំដាប់ថ្នាក់ អំពីបទបញ្ញា និងនីតិវិធី ក្រម-សីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោតផ្សេងៗទៀត ដែលចេញដោយ គ.ជ.ប ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព និងបញ្ចៀសបាននូវការចោទ-ប្រកាន់ផ្សេងៗ ពិសេសការបណ្ដុះបណ្ដាលមន្ត្រីគណៈ-កម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (គ.ក.ប/គ.ក.រ) ដែលជាយន្តការនៃកិច្ចចាប់ផ្ដើមប្រតិបត្តិការបោះឆ្នោត ឬអាចហៅថាប្រតិបត្តិករដំបូងនៃការបោះឆ្នោត
- ត្រូវជំរុញការអប់រំប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការបោះឆ្នោត ដែលជាស្នូលនៃការអនុវត្តនយោបាយប្រជាធិបតេយ្យ សេរី ពហុបក្ស និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងដំណើរការរៀបចំការបោះឆ្នោតឱ្យបានកាន់តែទូលំទូលាយ ដោយយកចិត្តទុកដាក់លើការផលិត និងការកែលម្អសម្ភារអប់រំអ្នកបោះឆ្នោត និងបង្កើនកិច្ចសហការល្អជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្នុងការងារអប់រំអ្នកបោះឆ្នោត
- ត្រូវបន្តពង្រឹងទំនាក់ទំនងល្អជាមួយនឹងគ្រប់ស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងស្នើសុំឱ្យមានកិច្ចសហការ និងការគាំទ្រក្នុងដំណើរការបោះឆ្នោតនៅពេលខាង-មុខ និងបន្តបន្ទាប់ ឱ្យកាន់តែមានភាពប្រសើរឡើង
- ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីជំរុញការចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដើម្បីចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត និងពង្រឹងការអនុវត្តច្បាប់ក្នុងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត ជូនប្រជាពលរដ្ឋសម្រាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត



មន្ត្រី គ.ជ.ប អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

- ត្រូវបន្តពង្រឹងទំនាក់ទំនង និងកិច្ចសហការល្អជាមួយអាជ្ញាធរដែនដី និងកងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់-ថ្នាក់ ដើម្បីរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្ដាប់-ធ្នាប់សាធារណៈក្នុងដំណើរការរៀបចំការបោះឆ្នោត
- ត្រូវជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីគណ-បក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ ក្នុងដំណើរការរៀបចំការបោះឆ្នោត។

សន្និបាតរយៈពេល ២ថ្ងៃ បានបញ្ចប់ក្នុងលទ្ធផលផ្លែផ្កាដោយទទួលបានធាតុចូលល្អៗសម្រាប់កែលម្អបន្ថែមទៀតលើការរៀបចំការបោះឆ្នោតជាបន្តបន្ទាប់៕

# ឯកឧត្តម នុត សុខុម អនុប្រធាន គ.ជ.ប អញ្ជើញជាអធិបតីក្នុងពិធីបើកសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

កាលពីព្រឹកថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំពិធីបើកសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **នុត សុខុម** អនុប្រធាន គ.ជ.ប នៅសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង។



ឯកឧត្តម នុត សុខុម អនុប្រធាន គ.ជ.ប

ក្នុងពិធីបើកសន្និបាតនេះ ឯកឧត្តម **នុត សុខុម** បានលើកឡើងអំពីសមិទ្ធផលនៃការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ មានជាអាទិ៍៖

១- បានរៀបចំបទបញ្ញា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀតដើម្បីបម្រើឱ្យការបោះឆ្នោតស្របតាមច្បាប់ និងបទបញ្ញា ជាធរមាន។

២- បានចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋបានចំនួន ៩.៧១០.៦៥៥ នាក់ ក្នុងនោះស្ត្រី ចំនួន ៥.១៦១.៩០៩ នាក់ ទៅក្នុងបញ្ជីបោះឆ្នោត។

៣- បានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ចំនួន ១៨ គណបក្សនយោបាយ។

៤- បានទទួលស្គាល់ភ្នាក់ងារគណបក្សនយោបាយ ចំនួន ៥៧.០១២ នាក់ ក្នុងនោះស្ត្រី ចំនួន ១៦.៦២៤ នាក់។

៥- បានអនុញ្ញាតជូនអ្នកសង្កេតការណ៍បោះឆ្នោតជាតិ ចំនួន ៨៩.៥៦២ នាក់ ស្ត្រី ចំនួន ៥២.៦៥២ នាក់ ក្នុងនោះអ្នកសង្កេតការណ៍ចល័តមានចំនួន ១៥៧ នាក់ ស្ត្រី ចំនួន ៤៧ នាក់ មកពី ១៣៤ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ចំណែកឯអ្នកសង្កេតការណ៍អន្តរជាតិមានចំនួន ៦០៤ នាក់ ស្ត្រី ចំនួន ១៧០ នាក់ រួមមាន ប្រតិភូអន្តរជាតិដែលអញ្ជើញដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ២៦៨ នាក់ មកពី ២៦ ស្ថាប័ន ប្រតិភូអន្តរជាតិដែលអញ្ជើញដោយវេទិកាសម្ព័ន្ធសង្គមស៊ីវិល ចំនួន ៦៥ នាក់ មកពី ១២ ស្ថាប័ន ប្រតិភូអន្តរជាតិដែលអញ្ជើញដោយ គ.ជ.ប ចំនួន ២៤ នាក់ អ្នកសង្កេតការណ៍អន្តរជាតិ ដែលស្នើសុំដោយផ្ទាល់មក គ.ជ.ប ចំនួន ៤៧ រូប និងភ្ញៀ-



ភាគីពាក់ព័ន្ធអញ្ជើញចូលរួមក្នុងពិធីបើកសន្និបាត

ពិសេស ចំនួន ១៨ នាក់ អញ្ជើញដោយ គ.ជ.ប ចំនួន ១១ នាក់ និងស្នើសុំដោយផ្ទាល់មក គ.ជ.ប ចំនួន ៧ នាក់ ព្រមទាំងអ្នកបកប្រែសម្រាប់អ្នកសង្កេតការណ៍អន្តរជាតិ ចំនួន ១៨២ នាក់។

៦- បានទទួលស្គាល់ និងចេញបណ្ណអ្នកសារព័ត៌មានជាតិសរុប ចំនួន ១.២៨៩ នាក់ស្ត្រី ចំនួន ១៨៥ នាក់ មកពី ១២៧ អង្គភាព។ ចំណែកឯអ្នកសារព័ត៌-មានអន្តរជាតិមានចំនួន ១៣៧ នាក់ ស្ត្រី ចំនួន ៣០ នាក់ មកពី ៣៨ អង្គភាព។



ថ្នាក់ដឹកនាំ និងមន្ត្រី គ.ជ.ប អញ្ជើញចូលរួមក្នុងពិធីបើកសន្និបាត

៧- បានចែក និងផ្តល់បណ្ណព័ត៌មានអ្នកបោះឆ្នោត ជូនដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបាន សរុប ចំនួន ៩.២០៩.១៧៧ សន្លឹក ស្មើនឹង ៩៤.៨៤ ភាគរយ។

៨- បានចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ជូនអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត សរុប ចំនួន ២០១.៧៧៨ ឯកសារ។

៩- បើទោះបីជាមានការញុះញង់តាមបណ្តាញសង្គម មិនឱ្យប្រជាពលរដ្ឋទៅបោះឆ្នោត និងឱ្យគូសបំផ្លាញសន្លឹកឆ្នោតចោលក៏ដោយ យើងឃើញថា ចំនួនប្រជាពលរដ្ឋដែលបានអញ្ជើញទៅបោះឆ្នោតមានចំនួន ៨.២១៤.៤៣០ នាក់ ស្មើនឹង ៨៤,៥៩ ភាគរយ នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុប (ចំនួន ៩.៧១០.៦៥៥ នាក់) បានទៅបោះឆ្នោត សម្តែងឆន្ទៈរបស់ពួកគាត់ដោយសេរី និងអនុវត្ត



គណៈអធិបតីអញ្ជើញចូលរួមក្នុងពិធីបើកសន្និបាត

សិទ្ធិបោះឆ្នោតរបស់ខ្លួនប្រកបដោយសុវត្ថិភាព គ្មានការបំភិតបំភ័យ គ្មានការគំរាមកំហែង និង គ្មានអំពើហិង្សា។

១០- ការដាក់ ការទទួល និងការដោះស្រាយពាក្យ-បណ្តឹងសរុប ចំនួន ៣៨ បណ្តឹង។

១១- បានដាក់ឱ្យប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននូវកម្មវិធីចំនួន៤ គឺ៖

- កម្មវិធីរៀបចំបញ្ជីគណបក្សនយោបាយឈរ-ឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ
- កម្មវិធីចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត
- កម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត
- កម្មវិធីគ្រប់គ្រងសំណុំរឿង និងរបាយការណ៍ពាក់ព័ន្ធនឹងពាក្យបណ្តឹង។

១២- បានផ្សព្វផ្សាយលទ្ធផលបោះឆ្នោតបឋម លទ្ធផលបោះឆ្នោតបណ្តោះអាសន្ន និងប្រកាសផ្សាយលទ្ធផលបោះឆ្នោតផ្លូវការ តាមទូរទស្សន៍ជាតិកម្ពុជា វិទ្យុជាតិ និងតាមអ៊ីនធឺណិត តាមរយៈវេបសាយដែលមានអាសយដ្ឋាន electresult.nec.gov.kh, Mobile App ( NEC KH និង CAMNEC NEWS ), Channel YouTube និងតាម Facebook Page របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ឯកឧត្តមអនុប្រធាន គ.ជ.ប បានគូសបញ្ជាក់ថា សមិទ្ធផល

ការងារខាងលើនេះ អាចសម្រេចទៅបានអាស្រ័យលើការប្តេជ្ញាចិត្តគោរព និងអនុវត្តបានត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ប្រតិទិន និងផែនការមេ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួនទៀត។ ជាមួយគ្នានេះផងដែរក៏មានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ទទួលខុសត្រូវខ្ពស់ ចូលរួមទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ព្រមទាំងប្រាជ្ញាស្មារតី ក្នុងការអនុវត្តការងារតាមតួនាទី និងភារកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងមន្ត្រីលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គួបផ្សំនឹងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលរួមមានការចូលរួមដោយសេចក្តីគោរពរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជា គណបក្សនយោបាយ គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ប្រទេសចិន និងប្រទេសជប៉ុន។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានផ្តល់កិច្ចសហការល្អ ដោយអនុញ្ញាតឱ្យបុគ្គលិកអប់រំចូលបម្រើការងារជាមន្ត្រីបោះឆ្នោត និងបានផ្តល់ទីតាំងសាលារៀនដើម្បីធ្វើជាទីស្នាក់ការគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងទីតាំងការិយាល័យបោះឆ្នោត។

ឯកឧត្តម **នុត សុខុម** បានថ្លែងទៀតថា ទោះបីជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ សម្រេចបាននូវលទ្ធផលជោគជ័យយ៉ាងណាក្តី ក៏យើងនៅតែសង្កេតឃើញថានៅមានចំណុចខ្វះខាតមួយចំនួន ដែលយើងទាំងអស់គ្នាត្រូវតែចូលរួមចំណែកដោះស្រាយតាមរយៈអង្គសន្និបាតនេះ។

ឯកឧត្តម បានស្នើឱ្យសមាជិកអង្គសន្និបាតទាំងអស់ផ្តោតការយកចិត្តទុកដាក់ក្នុងការចូលរួមពិភាក្សាឱ្យបានផុលផុស ដោយលើកយកបញ្ហាប្រឈមសំខាន់ៗ ផ្តល់ជាយោបល់ ឬលើកជាសំណូមពរ ឬអនុសាសន៍ លើប្រធានបទធំៗ ចំនួន ៥ គឺ៖

- ទី១- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ទី២- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ និងនីតិវិធីនៃការដាក់ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- ទី៣- ការឃោសនាបោះឆ្នោត និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ក្នុងដំណើរការឃោសនាបោះឆ្នោត
- ទី៤- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ទី៥- ការបណ្តុះបណ្តាល និងការអប់រំអ្នកបោះឆ្នោត។

អនុសាសន៍តាមរយៈកិច្ចពិភាក្សា គឺជាធាតុចូលយ៉ាងសំខាន់ក្នុងការធ្វើឱ្យកាន់តែល្អប្រសើរបន្ថែមទៀត លើដំណើរការរៀបចំ ចាត់ចែង គ្រប់គ្រងការបោះឆ្នោតនៅពេលខាងមុខជាបន្តបន្ទាប់៕

# លទ្ធផលនៃសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

យើងមិនអាចធ្វើឱ្យការបោះឆ្នោតមួយល្អឥតខ្ចោះនោះទេ ប៉ុន្តែយើងអាចធ្វើការកែលម្អជាបន្តបន្ទាប់ ដើម្បីឱ្យការបោះឆ្នោតលើកក្រោយៗកាន់តែល្អប្រសើរ។ និយាយដល់ចំណុចនេះ គឺយើងត្រូវការជាចាំបាច់នូវការចូលរួមរបស់ភាគីពាក់ព័ន្ធទាំងអស់តាមរយៈការផ្តល់នូវធាតុចូលល្អៗជុំវិញដំណើរការរៀបចំការបោះឆ្នោត ជូនដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ ហេតុនេះហើយទើបនៅក្រោយការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត គ.ជ.ប តែងតែរៀបចំសន្និបាតបូកសរុបការងារ ដែលអនុញ្ញាតឱ្យបណ្តាភាគីពាក់ព័ន្ធទាំងអស់បានលើកជាមតិយោបល់ បង្ហាញនូវបទពិសោធន៍ផ្ទាល់ខ្លួនអំពីការបោះ-

ឆ្នោត និងពិភាក្សាគ្នា រកឱ្យឃើញនូវចំណុចខ្លាំង ព្រមទាំងចំណុចខ្វះខាតដែលត្រូវធ្វើការកែលម្អបន្ថែម។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដែលទើបបញ្ចប់ទៅនេះ ត្រូវបានកត់សម្គាល់ថាបានប្រព្រឹត្តទៅដោយរលូន និងជោគជ័យ ដែលអាចទទួលយកបានពីគ្រប់ភាគីចូលរួមក្នុងការបោះឆ្នោត។ បន្ទាប់ពីលទ្ធផលផ្លូវការត្រូវបានប្រកាស សន្និបាតបូកសរុបមួយត្រូវបាន គ.ជ.ប រៀបចំឡើងរយៈពេល ២ថ្ងៃ គឺនៅថ្ងៃទី១៤-១៥ ខែសីហា ឆ្នាំ២០២៣ នៅសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង។



ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប

នៅក្នុងសន្និបាត គណៈកម្មការរៀបចំ បានបែងចែកក្រុមពិភាក្សាចំនួន ៥ ក្រុម តាមជំនាញនីមួយៗ ដែលសមាជិកចូលរួមក្រុម រួមមានមន្ត្រី គ.ជ.ប ពាក់ព័ន្ធ តំណាងក្រសួង ស្ថាប័នមួយចំនួន តំណាងគណបក្សនយោបាយ និងតំណាងសមាគមអង្គការមិនមែនរដ្ឋាភិបាល។ សមាជិកដែលចូលរួម អាចលើកឡើងនូវគ្រប់បញ្ហាប្រឈមដែលខ្លួនជួបប្រទះក្នុងការបោះឆ្នោត ទាំងវិជ្ជមាន និងអវិជ្ជមាន និងលើកជាមតិយោបល់ជូនក្រុម ដើម្បីធ្វើការពិភាក្សាគ្នាឱ្យបានគ្រប់ជ្រុងជ្រោយ។ ហើយគ្រប់បញ្ហាដែលបានជួបប្រទះ និងដំណោះស្រាយដែលបានរកឃើញក្នុងក្រុមពិភាក្សា នឹងត្រូវកត់ត្រា ដើម្បីដាក់ជូនថ្នាក់ដឹកនាំ គ.ជ.ប ពិនិត្យ និងសម្រេច។

ជាលទ្ធផល ក្រោយកិច្ចពិភាក្សាយ៉ាងផុលផុសរយៈពេលមួយថ្ងៃ និងតាមរបាយការណ៍បូកសរុបរបស់ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ គ.ជ.ប សន្និបាតបានកត់សម្គាល់ចំណុចខ្លាំង ចំណុចខ្សោយ ការខ្វះខាត និងបញ្ហាប្រឈមមួយចំនួនក្នុងដំណើរការរៀបចំការបោះឆ្នោត ដែលត្រូវយកចិត្តទុកដាក់ធ្វើការកែលម្អ រួមមាន៖

**ទី១- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត៖**

- ការបន្តពង្រឹងកិច្ចសហការលើការងារស្រង់ស្ថិតិប៉ាន់ស្មានអ្នកចុះឈ្មោះ និងស្រង់ទិន្នន័យអ្នកបោះឆ្នោតឱ្យបានល្អ ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត
- ការកំណត់ទីតាំង និងកែសម្រួលទីតាំងការិយាល័យបោះឆ្នោត ពិសេសនៅឆ្នាំដែលមានការបោះឆ្នោតជាសកល ត្រូវពិនិត្យបន្ថែមអំពីស្ថានភាពទីតាំង និងសំណង់ ដើម្បីធានាបានសម្រាប់ការបោះឆ្នោត និងសុវត្ថិភាព
- ការរៀបចំបញ្ជីបោះឆ្នោតថ្មី ដើម្បីប្រើប្រាស់ស្របតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។

**ទី២- ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន និងនីតិវិធីនៃការដាក់ការទទួល និងការដោះស្រាយពាក្យបណ្តឹង និងការងារសន្តិសុខ ក្នុងដំណើរការបោះឆ្នោត៖**

- ការកែសម្រួលបទបញ្ញា និងនីតិវិធីពាក់ព័ន្ធនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះទៅតាមច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត
- ការបន្តពង្រឹងការអនុវត្តការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជន



មន្ត្រី គ.ជ.ប អញ្ជើញចូលរួមក្នុងពិធីបិទសន្និបាត

ឈរឈ្មោះ តាមច្បាប់ និងបទបញ្ជា និងនីតិវិធី កំណត់ ពិសេសអំពីលក្ខខណ្ឌសម្រាប់គណបក្សនយោបាយ និងសម្រាប់បេក្ខជន

- ការកែសម្រួលបទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ដោយកំណត់ច្បាស់លាស់ប្រភេទនៃពាក្យបណ្តឹង សមត្ថកិច្ចដោះស្រាយ និងពេលវេលាកំណត់នៃការដោះស្រាយពាក្យបណ្តឹង
- ការបន្តពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារសេវាកម្មច្បាប់ និងវិវាទកម្មគ្រប់ថ្នាក់ ដើម្បីជាមន្ត្រីបង្គោលជំនួយដល់ការបណ្តុះបណ្តាល និងជាជំនួយដល់ការងារទទួល និងការដោះស្រាយពាក្យបណ្តឹងនៅគ្រប់ថ្នាក់ ក្នុងការបោះឆ្នោត
- ការបន្ត និងបង្កើនកិច្ចសហការជាមួយស្ថាប័នអាជ្ញាធរមានសមត្ថកិច្ច គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្នុងការការពារសន្តិសុខសម្រាប់ការបោះឆ្នោត និងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

**ទី៣- ការឃោសនាបោះឆ្នោត ការងារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ៖**

- ការបន្តពង្រឹងការគោរពច្បាប់ បទបញ្ជា និងនីតិវិធី និងគោលការណ៍ទូទៅនៃការឃោសនាបោះឆ្នោត និងក្រមសីលធម៌ពាក់ព័ន្ធ ដែលសម្រេចដោយ គ.ជ.ប
- ការបន្តរៀបចំឱ្យមានយន្តការសម្របសម្រួលរវាងគណៈកម្មការរៀបចំការបោះឆ្នោតអាជ្ញាធរមានសមត្ថកិច្ច និងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដើម្បីបង្ការ ទប់ស្កាត់ និងដោះស្រាយបញ្ហាដែលកើតមានពេលឃោសនាបោះឆ្នោត
- ការកំណត់អំពីនិយមន័យ និងទំហំនៃការហែក្បួនឃោសនាបោះឆ្នោតព្រមទាំងតម្រាយផ្លូវសម្រាប់ការហែក្បួន ដើម្បីបញ្ចៀសនូវរាល់ការប៉ះទង្គិចរវាងក្បួនឃោសនារបស់គណបក្សពីរ ឬច្រើន ព្រមទាំងរក្សាបាននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- ការពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្ការ និងទប់ស្កាត់អំពើល្មើស និងការផ្សព្វផ្សាយញុះញង់ជ្រុលនិយមដែលធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត និងបង្កការរំខានដល់ដំណើរការបោះឆ្នោត
- ការបន្តផលិតព័ត៌មាន ការបំភ្លឺ បកស្រាយ ពិតត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលា ដើម្បីផ្សព្វផ្សាយជូនសាធារណជន អ្នកបោះឆ្នោត និងជាប្រភពឯកសារសម្រាប់ការផ្សាយបន្ត។

**ទី៤- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត៖**

- ការពង្រឹងការទទួលខុសត្រូវក្នុងការបំពេញទម្រង់បែបបទដែលប្រើនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឱ្យបានត្រឹមត្រូវពេញលេញ និងគ្រប់ចំនួន និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឡើងវិញមុននឹងវេចខ្ចប់ បិទផ្សាយ និងបញ្ជូនទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដើម្បីបូកសរុបជាលទ្ធផលបឋម
- ការពង្រឹងកិច្ចប្រតិបត្តិការរបស់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត។

**ទី៥- ការបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត៖**

- ការពង្រឹងសមត្ថភាពទាំងទ្រឹស្តី ទាំងបច្ចេកទេស និងការអនុវត្តដល់គ្រូបង្គោលគ្រប់លំដាប់ថ្នាក់ និងបំពាក់សម្ភារបច្ចេកទេសសមស្រប
- ការបណ្តុះបណ្តាលទៅតាមដំណាក់កាល ត្រូវ



**សកម្មភាពក្នុងពិធីបិទសន្និបាត**

គោរពតាមប្រតិទិន និងរយៈពេលច្បាស់លាស់ ៖

- យកចិត្តទុកដាក់ការបណ្តុះបណ្តាលដោយផ្ទាល់មានលំហាត់ និងការអនុវត្ត
- ឯកសារមេរៀនត្រូវងាយយល់ និងចែកជូនឱ្យបានមុនពេលរៀនទាំងជាក្រដាស ឬជាច្បាប់ចម្លងទន់។

- ការអប់រំសាធារណជន និងការអប់រំអ្នកបោះឆ្នោតត្រូវធ្វើដោយច្រើនទម្រង់ ដោយផ្ទាល់ ដោយការបិទផ្សាយ ចែកផ្សាយ តាមប្រព័ន្ធផ្សព្វផ្សាយ តាមបណ្តាញសង្គម និងស្របតាមដំណាក់កាលនីមួយៗនៃការបោះឆ្នោត៖

- ខ្លឹមសារត្រូវច្បាស់លាស់ និងងាយយល់
- យកចិត្តទុកដាក់សហការជាមួយភាគីពាក់ព័ន្ធជាអាទិ៍ អាជ្ញាធរមានសមត្ថកិច្ច អង្គការមិនមែនរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយដើម្បីធ្វើការផ្សព្វផ្សាយសមស្របតាមកម្រិត និងមជ្ឈដ្ឋាន
- បន្តបញ្ជ្រាបការយល់ដឹងអំពីលទ្ធិប្រជាធិបតេយ្យ និងការបោះឆ្នោតក្នុងមជ្ឈដ្ឋានសិស្សនិស្សិតក្នុងគ្រឹះស្ថានសិក្សា។

**ទី៦- ការពង្រឹង និងធ្វើឱ្យប្រសើរឡើងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីជាជំនួយដល់ការងារគ្រប់គ្រង និងការងារបច្ចេកទេស ក្នុងការរៀបចំការបោះឆ្នោត៖**

- ការផ្គត់ផ្គង់កុំព្យូទ័រ និងសម្ភារ បរិក្ខារបច្ចេកទេសដែលមានគុណភាពខ្ពស់ និងគ្រប់គ្រាន់ដល់គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម
- ការកែលម្អកម្មវិធី ការកែលម្អរបៀបប្រើប្រាស់សេវាប្រតិបត្តិការ និងការគាំទ្រ
- ការងារថែទាំ និងការជួសជុលសម្ភារ បរិក្ខារ ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងទាន់ពេលវេលា
- ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្ត តាមរយៈការបណ្តុះបណ្តាលជំនាញបច្ចេកទេស។

សូមជម្រាបជូនថា សន្និបាតរយៈពេលពីរថ្ងៃនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប ឯកឧត្តម **នុត សុខុម** អនុប្រធាន គ.ជ.ប និងឯកឧត្តមជាសមាជិក គ.ជ.ប ទាំងអស់។ សមាជិកពេញអង្គនៃសន្និបាតរួមមាន ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត។ អញ្ជើញចូលរួមក្នុងសន្និបាតនេះផងដែររួមមាន តំណាងមកពីក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការ-ដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខា-ធិការដ្ឋានរដ្ឋសភា លេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត អគ្គបញ្ជាការដ្ឋាននៃកងយោធ-ពលខេមរភូមិន្ទ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកដ្ឋានរដ្ឋបាល និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ មន្ទីរ អង្គភាពនៃខេត្តបាត់ដំបង ដែលរួមមានស្នងការដ្ឋាននគរបាលខេត្ត តំបន់ប្រតិបត្តិការសឹករងខេត្ត បញ្ជា-ការដ្ឋានកងរាជអាវុធហត្ថខេត្ត គណៈអភិបាលក្រុង និងស្រុកនៃខេត្តបាត់ដំបង តំណាងគណបក្សនយោបាយដែលបានឈរ-ឈ្មោះបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាលសង្កេតការណ៍បោះ-ឆ្នោតជាតិ និងអន្តរជាតិ ទីប្រឹក្សានៃទីភ្នាក់ងារ JICA របស់ជប៉ុនប្រចាំនៅ គ.ជ.ប និងភ្ញៀវពិសេសនៃការបោះឆ្នោត ដែលសរុបទាំងអស់មានចំនួនប្រមាណ ៥៧៤ នាក់៕

# កម្រងរូបភាពសកម្មភាពពិភាក្សាតាមក្រុម និងតាមប្រធានបទជំនាញ ចំនួន ៥ ក្នុងពិធីសន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

សកម្មភាពពិភាក្សាក្រុមទី១ "ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត"













## សកម្មភាពពិភាក្សាក្រុមទី២ "ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនឈរឈ្មោះ និងនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង"








## សកម្មភាពពិភាក្សាក្រុមទី៣ "ការឃោសនាបោះឆ្នោត និងការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយ ក្នុងដំណើរការឃោសនាបោះឆ្នោត"













## សកម្មភាពពិភាក្សាក្រុមទី៤ "ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត"













## សកម្មភាពពិភាក្សាក្រុមទី៥ "ការបណ្តុះបណ្តាល និងការអប់រំអ្នកបោះឆ្នោត"
















ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរសព្ទ (Tel) : (+855) 23 235 271
អ៊ីម៉ែល(Email): info@nec.gov.kh
Website: www.nec.gov.kh, voterlist.nec.gov.kh
Facebook/Youtube: National Election Committee
APP: NEC KH, CamNEC News